**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣✵៥

# កិច្ចព្រមព្រៀង

ស្តីពីការព្យួរកិច្ចសន្យាការងាររវាងតំណាងនិយោជិក និងក្រុមហ៊ុន អឺបៅអេស៊ា កាលពីថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០២០ វេលាម៉ោង ៨ និង ៤០នាទីព្រឹក មានការប្រជុំស្តីពីការព្យួរកិច្ចសន្យាការងារ នៅក្រុមហ៊ុន អឺបៅអេស៊ា មានទីតាំងនៅភូមិត្រពាំងសេះ សង្កាត់គោកចក ខេត្តសៀមរាប។

សមាសភាពដែលចូលរួមក្នុងអង្គប្រជុំមាន:

| ក. ភាគីនិយោជក (តំណាងឲ្យក្រុមហ៊ុន) | តួនាទី | លេខទូរស័ព្ទទំនាក់ទំនង |
|---|---|---|
| លោក ជា សេងហាក់ | ប្រធានផ្នែកធនធានមនុស្ស | 010 777 441 |

| ខ. ភាគីនិយោជិក(តំណាងឲ្យបុគ្គលិក) | តួនាទី | លេខទូរស័ព្ទទំនាក់ទំនង |
|---|---|---|
| កញ្ញា ឡុង ឆេងលាង | បុគ្គលិកផ្នែកលក់ | 010 604 247 |

ឆ្លងតាមការពិភាក្សាពន្យល់នូវគោលបំណងដែលពាក់ព័ន្ធនិងការព្យួរឲ្យបានសមស្របតាមសេចក្តីណែនាំលេខ: ០៤៥/២០កប/ស.ណ.ន.ល ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រប់ភាគីទាំងពីរបានឯកភាពយល់ព្រមព្យួរកិច្ចសន្យាការងារទាំងអស់ក្នុងរយៈពេល ០២ខែ ដោយគិតចាប់ពីថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០២០ ដល់ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០២០ ដោយទទួលប្រាក់ឧបត្ថមពីរាជរដ្ឋាភិបាលម្នាក់ៗចំនួន ៤០ដុល្លាអាមេរិកក្នុងរយៈពេលព្យួរកិច្ចសន្យាការងារនេះ។ សម្រាប់ក្រុមហ៊ុន មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់ប្រាក់ឧបត្ថមបន្ថែមទៅដល់បុគ្គលិកក្នុងពេលព្យួរកិច្ចសន្យាការងារនេះឡើយ ដោយសារតែក្រុមហ៊ុនទទួលរងផលប៉ះពាល់ដោយសារជម្ងឺកូវីដ ១៩ បាត់បង់ប្រាក់ចំណូល។

ការពិភាក្សានេះត្រូវបានបញ្ចប់នៅវេលាម៉ោង ៩ និង ១០នាទីព្រឹក នាថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០២០ ដោយមានការចុះហត្ថលេខាព្រមព្រៀងរបស់តំណាងទាំងអស់ដែលអាចយកជាការបាននៅចំពោះមុខច្បាប់។
កិច្ចព្រមព្រៀងខាងលើបង្ហាញពីព័ត៌មានពិត និងត្រឹមត្រូវរវាងភាគីដែលបានចុះហត្ថលេខាដូចខាងក្រោម:

| ភាគីនិយោជកតំណាងឲ្យនិយោជក | ភាគីតំណាងឲ្យនិយោជិក |
|---|---|
| ហត្ថលេខ/ស្នាមមេដៃ | ហត្ថលេខា/ស្នាមមេដៃ |
| ជា សេងហាក់ | ឡុង ឆេងលាង |